**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការគ្រប់គ្រងសន្តិសុខឯកជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងលើកទឹកចិត្តក្នុងការបង្កើតនិងការពង្រឹងសន្តិសុខឯកជនដើម្បីចូលរួមចំណែកក្នុងការថែរក្សាការពារទ្រព្យសម្បត្តិ អាយុជីវិតប្រជាជននិងការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីការបង្កើត ការគ្រប់គ្រង និងសកម្មភាពរបស់សន្តិសុខឯកជនគ្រប់ប្រភេទ។



www.pheakdeylaw.com

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះសន្តិសុខឯកជនគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៤.-**

វាក្យស័ព្ទដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចតទៅ៖

- **សន្តិសុខឯកជន** សំដៅដល់សន្តិសុខដែលបង្កើតឡើងដោយសហគ្រាសគ្រឹះស្ថាននានា។ សន្តិសុខឯកជនមានពីរប្រភេទគឺសន្តិសុខឯកជនដែលបង្កើតឡើងដោយក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជននិងសន្តិសុខឯកជនដែលបង្កើតឡើងដោយសហគ្រាសគ្រឹះស្ថាននានា ។
- **ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន** សំដៅដល់នីតិបុគ្គលដែលបានបង្កើតភ្នាក់ងារសន្តិសុខឯកជនដើម្បីផ្តល់សេវាសន្តិសុខដល់អតិថិជនដោយគិតថ្លៃឈ្នួល ។
- **សហគ្រាសគ្រឹះស្ថាននានា** សំដៅដល់ក្រុមហ៊ុននានាដែលមិនផ្តល់សេវាសន្តិសុខឯកជន គ្រឹះស្ថានសាធារណៈ គ្រឹះស្ថានឯកជន អង្គការមិនមែនរដ្ឋាភិបាលនានាដែលបង្កើតភ្នាក់ងារសន្តិសុខឯកជន ដើម្បីបម្រើការងារក្នុងសហគ្រាសគ្រឹះស្ថានរបស់ខ្លួន ។
- **ភ្នាក់ងារសន្តិសុខឯកជន** សំដៅដល់រូបវន្តបុគ្គលដែលត្រូវបានជ្រើសរើសដោយក្រុមហ៊ុន ឬសហគ្រាសគ្រឹះស្ថាននានាដើម្បីបម្រើការងារសន្តិសុខ ។
- **សេវាសន្តិសុខឯកជន** សំដៅដល់ការផ្តល់សេវាថែរក្សាការពារទ្រព្យសម្បត្តិ អាយុជីវិត និងការផ្តល់សេវាកម្មផ្សេងៗទៀតតាមការព្រមព្រៀង ។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា ៥.-**

ក្រសួងមហាផ្ទៃដោយមានអគ្គស្នងការដ្ឋាននគរបាលជាតិជាសេនាធិការ មានសមត្ថកិច្ចក្នុងការផ្តល់ការអនុញ្ញាតឱ្យក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៦.-**

អគ្គស្នងការដ្ឋាននគរបាលជាតិ មានភារកិច្ចលើកសំណើជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃពិនិត្យនិងសម្រេចលើកិច្ចការដូចខាងក្រោម ៖

- ផ្តល់ការហ្វឹកហ្វឺនបណ្តុះបណ្តាលជំនាញឯកទេសនិងច្បាប់ចាំបាច់នានាជាធរមានដល់ភ្នាក់ងារសន្តិសុខរបស់ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជននិងរបស់សហគ្រាសគ្រឹះស្ថាននានា
- អនុញ្ញាតឱ្យភ្នាក់ងារសន្តិសុខឯកជនរបស់ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជនប្រើសម្ភារៈ មធ្យោបាយបច្ចេកទេស សត្វ សម្រាប់បម្រើសកម្មភាពការពារសន្តិសុខ
- ចាត់មន្ត្រីនគរបាលជំនាញចុះសហការជាមួយក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន
- ព្រមាន ឬផ្អាកសកម្មភាពជាបណ្តោះអាសន្ន ឬដកហូតលិខិតអនុញ្ញាតប្រកបអាជីវកម្មរបស់ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជនដែលធ្វើសកម្មភាពល្មើសច្បាប់។



www.pheakdeylaw.com

**មាត្រា ៧.-**

រដ្ឋបាលរាជធានី ខេត្ត ដោយមានស្នងការដ្ឋាននគរបាលរាជធានី ខេត្តជាសេនាធិការ មានសមត្ថកិច្ចក្នុងការផ្តល់ការអនុញ្ញាតឱ្យសហគ្រាសគ្រឹះស្ថាននានាបង្កើតភ្នាក់ងារសន្តិសុខឯកជនសម្រាប់បម្រើការងារក្នុងសហគ្រាសគ្រឹះស្ថានរបស់ខ្លួន។

**មាត្រា ៨.-**

ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត មានភារកិច្ចលើកសំណើជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្តពិនិត្យនិងសម្រេចលើកិច្ចការដូចខាងក្រោម ៖

- អនុញ្ញាតឱ្យភ្នាក់ងារសន្តិសុខឯកជនរបស់សហគ្រាសគ្រឹះស្ថាននានាប្រើសម្ភារៈ មធ្យោបាយ បច្ចេកទេស សត្វ សម្រាប់បម្រើសកម្មភាពការពារសន្តិសុខ
- ចាត់មន្ត្រីនគរបាលជំនាញចុះសហការជាមួយសហគ្រាសគ្រឹះស្ថាននានា
- ព្រមាន ឬផ្អាកសកម្មភាពជាបណ្តោះអាសន្ន ឬដកហូតលិខិតអនុញ្ញាតបង្កើតភ្នាក់ងារសន្តិសុខរបស់សហគ្រាសគ្រឹះស្ថាននានាដែលធ្វើសកម្មភាពល្មើសច្បាប់។

## ជំពូកទី៣
## ការអនុញ្ញាតផ្តល់សេវាសន្តិសុខឯកជន
## និងការជ្រើសរើសភ្នាក់ងារសន្តិសុខឯកជន

**មាត្រា ៩.-**

បុគ្គលដែលមានបំណងប្រកបអាជីវកម្មផ្តល់សេវាសន្តិសុខឯកជន ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មនៅក្រសួងមហាផ្ទៃ ។

ចំពោះសហគ្រាសគ្រឹះស្ថាននានា ដែលជ្រើសរើសភ្នាក់ងារសន្តិសុខឯកជនសម្រាប់បម្រើការងារក្នុងសហគ្រាសគ្រឹះស្ថានរបស់ខ្លួន ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតនៅរដ្ឋបាលរាជធានី ខេត្តដែលសាមីសហគ្រាសគ្រឹះស្ថាននោះតាំងនៅ ។

**មាត្រា ១០.-**

លក្ខខណ្ឌនិងទម្រង់បែបបទនៃការដាក់ពាក្យស្នើសុំការអនុញ្ញាតប្រកបអាជីវកម្មផ្តល់សេវាសន្តិសុខឯកជននិងនិងការជ្រើសរើសភ្នាក់ងារសន្តិសុខឯកជន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ១១.-**

រាល់ការស្នើសុំការអនុញ្ញាតប្រកបអាជីវកម្មផ្តល់សេវាកម្មសន្តិសុខឯកជន និងការអនុញ្ញាតជ្រើសរើសភ្នាក់ងារសន្តិសុខឯកជនសម្រាប់បម្រើការងារនៅតាមសហគ្រាសគ្រឹះស្ថាននានា ត្រូវបង់កម្រៃសេវារដ្ឋបាលនៃការអនុញ្ញាតនិងកម្រៃសេវារដ្ឋបាលនៃកិច្ចសហការជាមួយសមត្ថកិច្ចនគរបាលជាតិ។

កម្រៃសេវារដ្ឋបាលនៃការអនុញ្ញាតនិងកម្រៃសេវារដ្ឋបាលនៃកិច្ចសហការជាមួយសមត្ថកិច្ចនគរបាលជាតិ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



www.pheakdeylaw.com

## ជំពូកទី៤
## ភារកិច្ចរបស់ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន
## និងសហគ្រាសគ្រឹះស្ថាននានា

**មាត្រា ១២.-**

ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជនមានភារកិច្ចដូចខាងក្រោម៖

- សុំការអនុញ្ញាតឱ្យភ្នាក់ងារសន្តិសុខឯកជនប្រើឧបករណ៍ សម្ភារៈ បច្ចេកទេស មធ្យោបាយ ឬសត្វសម្រាប់បម្រើសកម្មភាពការពារសន្តិសុខ
- គោរពតាមការកំណត់របស់អគ្គស្នងការដ្ឋាននគរបាលជាតិអំពីជំនាញសន្តិសុខ
- រៀបចំផែនការរួមអំពីសកម្មភាពការពារសន្តិសុខសណ្តាប់ធ្នាប់របៀបរៀបរយសម្រាប់បម្រើអតិថិជន
- រៀបចំផែនការការពារទីតាំង ទ្រព្យសម្បត្តិ និងអាយុជីវិតរបស់អតិថិជន តាមករណីជាក់ស្តែងនីមួយៗ
- សុំការអនុញ្ញាតដើម្បីបណ្តុះបណ្តាលភ្នាក់ងារសន្តិសុខឯកជនពីអគ្គស្នងការដ្ឋាននគរបាលជាតិ
- ផ្តល់របាយការណ៍ប្រចាំខែអំពីសកម្មភាពរបស់ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជនជូនអគ្គស្នងការដ្ឋាននគរបាលជាតិ
- សុំកិច្ចអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ចក្នុងករណីចាំបាច់
- ត្រូវធានារ៉ាប់រងលើរបបសន្តិសុខសង្គមដល់ភ្នាក់ងារសន្តិសុខឯកជនតាមច្បាប់ជាធរមាន
- អនុវត្តការផ្តល់សេវាសន្តិសុខឯកជនស្របតាមច្បាប់ជាធរមាន
- សហការផ្តល់ភ្នាក់ងារសន្តិសុខតាមសំណើរបស់អគ្គស្នងការដ្ឋាននគរបាលជាតិក្នុងករណីចាំបាច់។

**មាត្រា ១៣.-**

សហគ្រាសគ្រឹះស្ថាននានាមានភារកិច្ចដូចខាងក្រោម៖

- សុំការអនុញ្ញាតឱ្យភ្នាក់ងារសន្តិសុខឯកជនប្រើឧបករណ៍ សម្ភារៈ បច្ចេកទេស មធ្យោបាយ ឬសត្វ សម្រាប់បម្រើសកម្មភាពការពារសន្តិសុខ
- គោរពតាមការកំណត់របស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត
- រៀបចំផែនការការពារទីតាំង ទ្រព្យសម្បត្តិ និងអាយុជីវិត
- សុំការអនុញ្ញាតដើម្បីបណ្តុះបណ្តាលភ្នាក់ងារសន្តិសុខឯកជនតាមរយៈស្នងការដ្ឋាននគរបាលរាជធានី ខេត្ត
- ផ្តល់របាយការណ៍ប្រចាំខែអំពីសកម្មភាពរបស់ភ្នាក់ងារសន្តិសុខឯកជនជូនស្នងការដ្ឋាននគរបាលរាជធានី ខេត្ត
- សុំកិច្ចសហការពីអាជ្ញាធរមានសមត្ថកិច្ចក្នុងករណីចាំបាច់
- ត្រូវធានារ៉ាប់រងលើរបបសន្តិសុខសង្គមដល់ភ្នាក់ងារសន្តិសុខឯកជនតាមច្បាប់ជាធរមាន។

**មាត្រា ១៤.-**

ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន និងសហគ្រាសគ្រឹះស្ថាននានា ត្រូវផ្តល់អាទិភាពក្នុងការជ្រើសរើសអតីតមន្ត្រីនគរបាលជាតិ មន្ត្រីកងយោធពលខេមរភូមិន្ទ និងមន្ត្រីរាជការផ្សេងទៀតដែលចូលនិវត្តន៍ ហើយនៅមានកាយសម្បទាល្អអាចធ្វើការងារបាននិងមានប្រវត្តិរូបល្អឲ្យចូលបម្រើការជាភ្នាក់ងារសន្តិសុខរបស់ខ្លួន។



www.pheakdeylaw.com

**មាត្រា ១៥..**

ទីតាំងឬសហគ្រាសគ្រឹះស្ថាននានាដែលមានអ្នកចាំយាម តែមិនមានប្រើឧបករណ៍ សម្ភារៈ ដូចមានចែងក្នុងមាត្រា១២និងមាត្រា១៣នៃអនុក្រឹត្យនេះ ពុំចាំបាច់ស្នើសុំការអនុញ្ញាតទេ តែត្រូវជូនដំណឹងអំពីសមាសភាពនៃអ្នកចាំយាមមកប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ដែលមានទីតាំងឬសហគ្រាសគ្រឹះស្ថាននោះតាំងនៅ ។

**មាត្រា ១៦..**

ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជនឬសហគ្រាសគ្រឹះស្ថាននានាដែលទទួលបានការអនុញ្ញាតឱ្យធ្វើការងារសន្តិសុខឯកជនគ្មានសិទ្ធិដូចខាងក្រោម៖

- ប្រើអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ
- ជ្រើសរើសភ្នាក់ងារសន្តិសុខឯកជនជាមន្ត្រីរាជការស៊ីវិលឬកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទដែលមិនទាន់ចូលនិវត្តន៍
- ប្រើឯកសណ្ឋាន សញ្ញាស័ក្តិដូចឬស្រដៀងនឹងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទនិងរបស់ក្រសួង ស្ថាប័ននានារបស់រដ្ឋ ។

## ជំពូកទី៥
## ទណ្ឌកម្ម

**មាត្រា ១៧..**

ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជនឬសហគ្រាសគ្រឹះស្ថាននានា ដែលមិនអនុវត្តតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មដូចខាងក្រោម៖

- ព្រមានជាលាយលក្ខណ៍អក្សរ
- ផ្អាកសកម្មភាពជាបណ្តោះអាសន្ន
- ដកហូតលិខិតអនុញ្ញាតជាស្ថាពរ ។

**មាត្រា ១៨..**

ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជនដែលផ្តល់សេវាសន្តិសុខដោយគ្មានការអនុញ្ញាត ក្រសួងមហាផ្ទៃត្រូវបញ្ឈប់សកម្មភាពនោះជាបន្ទាន់ និងពិន័យអន្តរការណ៍ជាប្រាក់ ២០.០០០.០០០ (ម្ភៃលាន)រៀល ។

សហគ្រាសគ្រឹះស្ថាននានាដែលជ្រើសរើសសន្តិសុខឯកជនដោយគ្មានការអនុញ្ញាត រដ្ឋបាលរាជធានី ខេត្ត ត្រូវបញ្ឈប់សកម្មភាពនោះជាបន្ទាន់ និងពិន័យអន្តរការណ៍ជាប្រាក់ ១០.០០០.០០០ (ដប់លាន)រៀល ។

ក្នុងករណីនេះ ក្រសួងមហាផ្ទៃ ឬរដ្ឋបាលរាជធានី ខេត្តអាចកសាងសំណុំរឿងបញ្ជូនទៅតុលាការផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា ១៩..**

ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជននិងសហគ្រាសគ្រឹះស្ថាននានា ដែលបានទទួលការអនុញ្ញាតឱ្យផ្តល់សេវាសន្តិសុខឯកជន ឬជ្រើសរើសភ្នាក់ងារសន្តិសុខឯកជនមុនពេលអនុក្រឹត្យនេះចូលជាធរមាននៅតែមានសិទ្ធិធ្វើសកម្មភាពបន្តទៀត ប៉ុន្តែត្រូវមកបំពេញតាមលក្ខខណ្ឌ និងបែបបទបន្ថែមក្នុងរយៈពេលយ៉ាងយូរ ០៦(ប្រាំមួយ)ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ។



www.pheakdeylaw.com

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា ២០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ២១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**ស ខេង**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com